# របាយការណ៍គ្រប់គ្រងប្រចាំឆ្នាំ ២០២២

# ANNUAL REPORT 2022

# របាយការណ៍សកម្មភាព ឆ្នាំ២០២២ និងត្រីមាសទី១ ឆ្នាំ២០២៣

(មេសា ២០២២ - កុម្ភៈ ២០២៣)

**០១. ការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធាន និងហេរញ្ញិក** (៣០ មីនា ២០២២)

ក្រុមប្រឹក្សាប្រតិបត្តិអាណត្តិទី៤ បានធ្វើការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធាន និងហេរញ្ញិក ក្រោមការរៀបចំរបស់គណៈកម្មការរៀបចំការបោះឆ្នោត។ ក្រុមប្រឹក្សាប្រតិបត្តិអាណត្តិទី៤ មានសមាសភាពដូចខាងក្រោម៖

១. លោកមជ្ឈត្តករ សាន គីរី ប្រធានក្រុមប្រឹក្សាប្រតិបត្តិ និងប្រធាន ម.ជ.ម.

២. លោកមជ្ឈត្តករ គឹម សាន អនុប្រធានក្រុមប្រឹក្សាប្រតិបត្តិ និងអនុប្រធាន ម.ជ.ម.

៣. លោកមជ្ឈត្តករ លឹម វាសនា ហេរញ្ញិកនៃ ម.ជ.ម.

៤. លោកមជ្ឈត្តករ ញាន សុមុន្និន្ទ សមាជិកក្រុមប្រឹក្សាប្រតិបត្តិ

៥. លោកមជ្ឈត្តករ សូ មូស្សេន្នី សមាជិកក្រុមប្រឹក្សាប្រតិបត្តិ

៦. លោកមជ្ឈត្តករ តែ ពន្លឺ សមាជិកក្រុមប្រឹក្សាប្រតិបត្តិនិង

៧. លោក វ៉ាន់ យុវទេព តំណាងសមាគមសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា និងសមាជិកក្រុមប្រឹក្សាប្រតិបត្តិ។

ក្នុងនោះក្រុមប្រឹក្សាប្រតិបត្តិអាណត្តិទី៣ ក៏បានធ្វើការប្រគល់តំណែង តួនាទី និងភារកិច្ចជូនដល់ក្រុមប្រឹក្សាប្រតិបត្តិអាណត្តិទី៤ ផងដែរ។





**០២. សិក្ខាសាលាអនឡាញស្តីពី "វិជ្ជាជីវៈមជ្ឈត្តករនៅកម្ពុជា"** (២១ មេសា ២០២២)

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ ម.ជ.ម. បានរៀបចំសិក្ខាសាលាតាមប្រព័ន្ធអនឡាញមួយ ដែលមានវត្តមានរបស់លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. និងលោកមជ្ឈត្តករ គឹម សាន អនុប្រធាន ម.ជ.ម. ជាវាគ្មិនកិត្តិយស ក្នុងការធ្វើបទបង្ហាញលម្អិតអំពី៖ តើអ្វីជាមជ្ឈត្តការ? តើនរណាជាមជ្ឈត្តករ? តើមជ្ឈត្តករមានអំណាចអ្វីខ្លះ? តើធ្វើដូចម្តេចដើម្បីក្លាយជាមជ្ឈត្តករ?តើមជ្ឈត្តករមានវិសមិតភាពជាមួយមុខងារអ្វីខ្លះ?
សិក្ខាសាលាអនឡាញបានប្រព្រឹត្តទៅយ៉ាងរលូន និងមានសាធារណជនជាច្រើនបានចូលរួម ហើយបង្ហាញអំពីចំណាប់អារម្មណ៍របស់ខ្លួនលើវិជ្ជាជីវៈមួយនេះ។

## ០៣. អគ្គលេខាធិការនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានលាលែងពីតំណែង (២៩ មេសា ២០២២)

លោក ឌិន ស៊ីដែន អគ្គលេខាធិការនៃ ម.ជ.ម. បានលាលែងពីតំណែង។ ក្រុមប្រឹក្សាប្រតិបត្តិ ក្នុងនាម ម.ជ.ម. បានថ្លែងអំណរគុណសម្រាប់ការខិតខំប្រឹងប្រែង ការចូលរួមចំណែក និងសមិទ្ធផលដែលសម្រេចបានដ៏ល្អប្រសើរនាឆ្នាំកន្លងមកសម្រាប់ ម.ជ.ម. ។ ជាចុងក្រោយ ម.ជ.ម. សូមជូនពរឲ្យរូបលោកទទួលបានតែសំណាងល្អ និងជោគជ័យលើគោលដៅបន្ទាប់របស់លោក។





## ០៤. វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់៥ កម្រិតបឋម (៣០ មេសា ២០២២)

ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការពាណិជ្ជកម្ម ជំនាន់៥ ក្រោមអធិបតីភាពរបស់ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. នៅសណ្ឋាគារកាំបូឌីយ៉ាណា។ លោកប្រធាន បានមានប្រសាសន៍ថា៖ ការរៀបចំឡើងនូវ "វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់៥" នេះ ជាសកម្មភាពមួយក្នុងចំណោមសកម្មភាពនានា ដែលមជ្ឈមណ្ឌលខិតខំជំរុញ ក្នុងគោលបំណងដើម្បីសម្រេចឲ្យបាននូវបេសកម្មរបស់ខ្លួន ក្នុងការធានាគុណភាពនៃដំណើរការមជ្ឈត្តការនៅកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងអនុក្រឹតស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ ម.ជ.ម.។





## ០៥. វគ្គបណ្តុះបណ្តាលអំពី "ការតាក់តែងមជ្ឈត្តវិនិច្ឆ័យ" (០៦ ឧសភា ២០២២)

នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ ម.ជ.ម. បានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់សមាជិកជាមជ្ឈត្តករ ដោយយោងទៅតាមស្មារតីនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងបទបញ្ជាផ្ទៃក្នុងរបស់ ម.ជ.ម. ក្នុងការបន្តពង្រឹងសមត្ថភាពរបស់មជ្ឈត្តករដែលបានចុះបញ្ជីនៅ ម.ជ.ម. ព្រមទាំងបើកឱកាសឱ្យរូបវន្តបុគ្គលដទៃដែលមានបំណងពង្រឹងជំនាញរបស់ខ្លួនលើការ "តាក់តែងមជ្ឈត្តវិនិច្ឆ័យ" នៅឯសណ្ឋាគារកាំបូឌីយ៉ាណា ក្រោមអធិបតីភាពរបស់ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. និងលោកមជ្ឈត្តករ Johnny Tan សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់របស់ ម.ជ.ម. ជាគ្រូឧទ្ទេស។

  

## ០៦. <u>ពិធីប្រគល់វិញ្ញាបនបត្រដល់បេក្ខជនដែលបានប្រឡងជាប់វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម</u> (០៦ ឧសភា ២០២២)

នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ ម.ជ.ម. បានរៀបចំពិធីប្រគល់វិញ្ញាបនបត្រ ក្រោមអធិបតីភាពរបស់ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. ដល់បេក្ខជនដែលបានប្រឡងជាប់វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម៖

១. ជំនាន់ទី៣ កម្រិតបឋម កម្រិតមធ្យម កម្រិតឧត្តម

២. ជំនាន់ទី៤ កម្រិតបឋម កម្រិតមធ្យម កម្រិតឧត្តម និង

៣. បេក្ខជនដែលប្រឡងជាប់ការប្រឡងដើម្បីទទួលបានលក្ខណសម្បត្តិដូចមានចែងក្នុងប្រការ ១២.១ (ឃ) នៃបទបញ្ជាផ្ទៃក្នុង ម.ជ.ម. ។

  

## ០៧. <u>ពិធីជួបជុំបង្កើនទំនាក់ទំនង រវាងមជ្ឈត្តករ និងសហគមអ្នកជំនួញ</u> (០៦ ឧសភា ២០២២)

នៅល្ងាចថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ ម.ជ.ម. បានរៀបចំពិធីជួបជុំបង្កើនទំនាក់ទងរវាងមជ្ឈត្តករ និងសហគមអ្នកជំនួញ នៅឯសណ្ឋាគារកាំបូឌីយ៉ាណា ដែលមានការចូលរួមពីសំណាក់ សមាជិក ម.ជ.ម. អ្នកប្រកបវិជ្ជាជីវៈច្បាប់ពាណិជ្ជករ និងសិក្ខាកាមនៃវគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការរបស់ ម.ជ.ម.។ ក្នុងកម្មវិធីនេះផងដែរ ម.ជ.ម. បានទទួលការចូលរួមគាំទ្រកម្មវិធីចំនួនប្រាំពីរស្ថាប័ន រួមមាន៖

១. ក្រុមមេធាវី ដឺ ហ្លេក

២. ការិយាល័យមេធាវីសុកស៊ីផាន់ណា និងសហការី

៣. ក្រុមមេធាវី ស្គាយវន្ត

៤. ក្រុមហ៊ុន DFDL

៥. ការិយាល័យមេធាវី ម៉ារ និងសហការី

៦. ការិយាល័យមេធាវី អេច ភី អរ

៧. សណ្ឋាគារកាំបូឌីយ៉ាណា

  

## ០៨. ការប្រឡង៖ ជំនាញតាក់តែងមជ្ឈត្តវិនិច្ឆ័យ (០៩ ឧសភា ២០២២)

នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ ម.ជ.ម. បានរៀបចំការប្រឡងលើការ តាក់តែងមជ្ឈត្តវិនិច្ឆ័យ ដែលមានការចូលរួមពីបេក្ខជនចំនួន ២២ (ម្ភៃពីរ) រូប និងទទួលបានជោគជ័យចំនួន ១៥ (ដប់ប្រាំ) រូប ។

  

## ០៩. ការតែងតាំងអគ្គលេខាធិការស្តីទី ម.ជ.ម. (០២ ឧសភា ២០២២)

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានសម្រេចតែងតាំង កញ្ញា ម៉ាត់ ហ្វានីតា ជាអគ្គលេខាធិការស្តីទី ដើម្បីបំពេញតួនាទី និងភារកិច្ចក្នុងនាមជាអគ្គលេខាធិការ របស់ ម.ជ.ម. ជំនួសឱ្យ លោក ឱន ស៊ីដែន  អតីតអគ្គលេខាធិការ របស់ ម.ជ.ម. ដែលបានលាឈប់ពីតំណែង។

## ១០. អនុស្សារណៈនៃការយោគយល់ជាមួយមជ្ឈមណ្ឌលនៃមជ្ឈត្តការអន្តរជាតិហុងកុង (១៦ មិថុនា ២០២២)

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានចុះអនុស្សារណៈនៃការយោគយល់ជាមួយមជ្ឈមណ្ឌលនៃមជ្ឈត្តការអន្តរជាតិហុងកុង (HKIAC) ក្នុងគោលបំណងធ្វើការជំរុញដល់ការប្រើប្រាស់មជ្ឈត្តការអន្តរជាតិឱ្យទៅជាយន្តការដែលពេញនិយមសម្រាប់ការដោះស្រាយវិវាទពាណិជ្ជកម្ម។

   

### ១១. ដំណើរទស្សនកិច្ចសិក្សារបស់និស្សិតជំនាញនីតិសាស្ត្រនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មកកាន់ ម.ជ.ម. (២៣ មិថុនា ២០២២)

នៅរសៀលថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ២០២២ កញ្ញា ម៉ាត់ ហ្វានីតា អគ្គលេខាធិការស្តីទីនៃ ម.ជ.ម. បានទទួលស្វាគមន៍ដំណើរទស្សនកិច្ចសិក្សារបស់និស្សិតជំនាញនីតិសាស្ត្រចំនួន ១៣ រូប ដឹកនាំដោយអ្នកគ្រប់គ្រងកម្មវិធីសិក្សាផ្នែកនីតិសាស្ត្រនៃមហាវិទ្យាល័យនីតិសាស្ត្ររបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា នៅទីស្នាក់ការមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ( ម.ជ.ម.)។ ការធ្វើទស្សនកិច្ចសិក្សានេះ គឺក្នុងគោលបំណងបង្កើននូវចំណេះដឹងផ្នែកមជ្ឈត្តការនៅកម្ពុជា ដែលពាក់ព័ន្ធទៅនឹងមុខវិជ្ជានៃកម្មវិធីសិក្សារបស់សាកលវិទ្យាល័យផង។ កញ្ញាអគ្គលេខាធិការស្តីទីបានធ្វើបទបង្ហាញអំពីវឌ្ឍនភាព និងតួនាទីរបស់ ម.ជ.ម. ក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា ព្រមទាំងធ្វើការចែករំលែកនូវបទពិសោធន ក៏ដូចជាការឆ្លើយសំណួរ និងសំណេះសំណាលជាមួយនិស្សិតទាំងអស់ផងដែរ។ អ្នកគ្រប់គ្រងកម្មវិធីសិក្សាផ្នែកនីតិសាស្ត្រនៃមហាវិទ្យាល័យនីតិសាស្ត្ររបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា បានជូនលិខិតថ្លែងអំណរគុណ ចំពោះ ម.ជ.ម. ដែលបានផ្តល់ឱកាសដល់និសិត្សក្នុងការទទួលបានការចែករំលែកចំណេះដឹងអំពីវិស័យមជ្ឈត្តការ និងពី ម.ជ.ម. ជាពិសេសចំពោះការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីក្រុមការងារអគ្គលេខាធិការដ្ឋានទាំងមូល។






### ១២. សិក្ខាសាលាស្តីពីការណែនាំអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (២៥ មិថុនា ២០២២)

នៅថ្ងៃសៅរ៍ ទី២៥ ខែមិថុនា ឆ្នាំ២០២២ លោកមជ្ឈត្តករ សាន គីរី ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជ-កម្ម (ម.ជ.ម.) បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងសិក្ខាសាលាស្តីពីការណែនាំអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា នៅឯសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សិក្ខាសាលានេះផងដែរ ត្រូវបានសហការរៀបចំឡើងដោយ ម.ជ.ម. និងកម្មវិធីបរិញ្ញាបត្រនីតិសាស្ត្រសិក្សាជាភាសាអង់គ្លេស ( ELBBL ) ដើម្បីជំរុញឲ្យនិស្សិតមានការយល់ដឹងពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលជាយន្តការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការឲ្យកាន់តែលម្អិត ។ សិក្ខាសាលានេះក៏មានការចូលរួមពីអនុប្រធាន ម.ជ.ម. ប្រធាន និងអនុប្រធានកម្មវិធីបរិញ្ញាបត្រនីតិសាស្ត្រសិក្សាជាភាសាអង់គ្លេស ព្រមទាំងនិស្សិតផ្នែកច្បាប់ជាច្រើនរូបទៀត។





### ១៣. <u>**ការប្រគល់វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មដល់បណ្ណាល័យ ក៏ដូចជាដេប៉ាត់ដឺម៉ង់បរិញ្ញាបត្រ និងអនុបណ្ឌិតផ្នែកច្បាប់**</u> (២៥ មិថុនា ២០២២)

បន្ទាប់ពីសិក្ខាសាលាស្តីពីការណែនាំអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានបញ្ចប់ លោកប្រធានបានប្រគល់វិធានស្តីពីមជ្ឈត្តការពាណិជ្ជកម្ម ម.ជ.ម. បទបញ្ជាផ្ទៃក្នុង ម.ជ.ម. និងក្រមសីលធម៌មជ្ឈត្តករ ជូនបណ្ណាល័យនីតិសាស្ត្រ ព្រមទាំងបណ្ណាល័យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដើម្បីជាជំនួយដល់និស្សិតដែលមានបំណងយល់ដឹងកាន់តែលម្អិតអំពី ម.ជ.ម. ព្រមទាំងដំណើរការមជ្ឈត្តការនៅ ម.ជ.ម.។





### ១៤. <u>**ការធ្វើបទបង្ហាញស្តីពី៖ កម្មវិធីប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២**</u> (១៤ សីហា ២០២២)

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២២ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. និង លោកស្រីបណ្ឌិត ម៉ែន វុឌ្ឍិការណ៍ បានផ្តល់កិត្តិយសជាវាគ្មិន ក្នុងការធ្វើបទបង្ហាញអំពីដំណាក់កាល នៃកម្មវិធីប្រកួត វិធាននៃកម្មវិធីប្រកួត អត្ថប្រយោជន៍នៃការ ចូលរួមប្រកួត ក៏ដូចជាការឆ្លើយតបនូវរាល់សំណួរទាក់ទងនឹងកម្មវិធីប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មផងដែរ។ គោលបំណងនៃការធ្វើបទបង្ហាញនេះគឺ ដើម្បីទាក់ទាញបេក្ខជនប្រកួតឱ្យចុះឈ្មោះចូលរួមកាន់តែច្រើនកុះករ។

### ១៥. <u>**ការចូលជួបសម្តែងការគួរសម និងបង្ហាញពីសមាសភាពក្រុមប្រឹក្សាប្រតិបត្តិអាណត្តិទី៤ ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**</u> (០៨ កញ្ញា ២០២២)

នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ លោកមជ្ឈត្តករ សាន គីរី ប្រធាន មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានដឹកនាំក្រុមប្រឹក្សាប្រតិបត្តិ និងក្រុមការងារអគ្គលេខាធិការដ្ឋាន ម.ជ.ម. ចូលជួបជាមួយឯកឧត្តម លី ច័ន្ទតុលា ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាអំពីលទ្ធភាពក្នុងកិច្ចសហការរៀបចំសិក្ខាសាលារួមគ្នា ស្របតាមអនុស្សរណៈយោគយល់រវាងស្ថាប័នទាំងពីរ នៅឯទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះដែរ លោកប្រធាន ម.ជ.ម. បានធ្វើការណែនាំអំពីសមាសភាពនៃក្រុមប្រឹក្សាប្រតិបត្តិអាណត្តិទី៤ របស់ ម.ជ.ម. ទាំង ៧រូប ព្រមទាំងបង្ហាញអំពីគម្រោងរៀបចំសិក្ខាសាលាមួយចំនួន។

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការគាំទ្រ និងរីករាយក្នុងការចូលរួមសហការរៀបចំសិក្ខាសាលាជាមួយ ម.ជ.ម. ។ ម.ជ.ម. និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានទិសដៅតែមួយក្នុងការពង្រឹង និងពង្រីកសហគមន៍មជ្ឈត្តការក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែប្រសើរឡើង ក្នុងគោលបំណងទាក់ទាញវិនិយោគិនជាតិ និងអន្តរជាតិ។






## ១៦. ការបើកកម្មវិធីប្រកួតមជ្ឈត្តការប្រតិជ្ជផ្នែកពាណិជ្ជកម្ម លើកទី២ ប្រចាំឆ្នាំ ២០២២ (៣០ កញ្ញា ២០២២)

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ម.ជ.ម. បានរៀបចំកម្មវិធីប្រកាសបើកដំណើរការប្រកួត និងផ្គូរផ្គងក្រុមនៃ "កម្មវិធីប្រកួតមជ្ឈត្តការប្រតិជ្ជផ្នែកពាណិជ្ជកម្ម លើកទី២ ប្រចាំឆ្នាំ ២០២២" ក្រោមអធិបតីភាពរបស់លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. ដោយមានការចូលរួមពីសំណាក់លោកមជ្ឈត្តករ គឹម សាន អនុប្រធាន ម.ជ.ម. ព្រមទាំងគណៈកម្មការរៀបចំកម្មវិធីប្រកួត គណៈកម្មការនិពន្ធសំណុំរឿងប្រតិជ្ជ គ្រូដឹកនាំ និងបេក្ខជនចូលរួមប្រកួតផងដែរ។ កម្មវិធីនេះត្រូវបានប្រព្រឹត្តឡើងដើម្បីប្រកាសបើកកម្មវិធីប្រកួត ការជួបសំណេះសំណាលជាមួយបេក្ខជនដែលបានចូលរួមប្រកួត ការផ្គូរផ្គងក្រុម និងចាប់ក្រុមជាមួយគ្រូដឹកនាំ។





## ១៧. ការពិភាក្សាការងារជាមួយឯកឧត្តម ជិន ម៉ាលីន រដ្ឋលេខាធិការក្រសួងយុត្តិធម៌ (០៥ តុលា ២០២២)

នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ លោកមជ្ឈត្តករ សាន គីរី ប្រធាន នៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម. ) បានដឹកនាំក្រុមប្រឹក្សាប្រតិបត្តិ និងក្រុមកាងារអគ្គលេខាធិការដ្ឋាន ម.ជ.ម. ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម ជិន ម៉ាលីន រដ្ឋលេខាធិការក្រសួងយុត្តិធម៌។

នៅក្នុងជំនួបពិភាក្សានេះ មានគោលបំណងសំខាន់ចំនួនពីរ គឺការណែនាំសមាសភាពសមាជិកក្រុមប្រឹក្សាប្រតិបត្តិនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម អាណត្តិទី៤ និងការរៀបចំយន្តការនៃកិច្ចសហការ គាំទ្រគ្នាទៅវិញទៅមករវាងស្ថាប័នទាំងពីរ លើការរៀបចំ និងអនុវត្តយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងជាពិសេសលើវិស័យមជ្ឈត្តកម្ម និងសន្ទានកម្មពាណិជ្ជកម្ម។






## ១៨. សិក្ខាសាលាស្តីពីមជ្ឈត្តករបន្ទាន់ និងនីតិវិធីពន្លឿន (០៧ តុលា ២០២២)

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២ ម.ជ.ម. បានរៀបចំសិក្ខាសាលាស្តីពី "មជ្ឈត្តករបន្ទាន់ និងនីតិវិធីពន្លឿន" ក្រោមអធិបតីភាពរបស់ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. ដែលមានវាគ្មិនកិត្តិយសសញ្ជាតិសិង្ហបុរីពីររូបចូលរួម គឺៈ លោកមជ្ឈត្តករ Johnny TAN និងលោកស្រី Yvonne Foo ដែលលោកទាំងពីរសុទ្ធសឹងជាមជ្ឈត្តករ និងសន្ទានការី មានបទពិសោធន៍យូរឆ្នាំ។ សិក្ខាសាលានេះផងដែរក៏មានវេទិកាពិភាក្សា ដែលមានការចូលរួមពីលោកមជ្ឈត្តករ គីរី សេរីវឌ្ឍ និងមជ្ឈត្តករ Jay Bryan COHEN ដែលលោកទាំងពីរជាមជ្ឈត្តករដែលមានបទពិសោធន៍ លើដំណើរការមជ្ឈត្តករបន្ទាន់ និងនីតិវិធីពន្លឿនផ្ទាល់ នៅ ម.ជ.ម.។





## ១៩. សិក្ខាសាលាស្តីពីការផ្សព្វផ្សាយជំរុញការប្រើប្រាស់មជ្ឈត្តការក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា (២៦ វិច្ឆិកា ២០២២)

នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២ លោកមជ្ឈត្តករ សាន គីរី ប្រធានរបស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) និង កញ្ញា ម៉ាត់ ហ្វានីតា អគ្គលេខាធិការស្តីទី ម.ជ.ម. បានផ្តល់បទបង្ហាញអំពីបច្ចុប្បន្នភាពរបស់ ម.ជ.ម. ក៏ដូចជាការពន្យល់លម្អិតអំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមយន្តការមជ្ឈត្តការ ព្រមទាំងបានចែករំលែកបទពិសោធន៍ល្អៗ ជូនចំពោះអ្នកចូលរួម និងនិស្សិត នៅសាហសាល B នៃសាកល វិទ្យាល័យជាតិគ្រប់គ្រង។ សិក្ខាសាលានេះផងដែរត្រូវបានចូលរួមសហការរៀបចំដោយក្រុមនិស្សិតបរិញ្ញាបត្រច្បាប់អន្តរជាតិនៃសាកលវិទ្យាជាតិគ្រប់គ្រង និងសមាគមសាលាត្រាជូ ផងដែរ។





## ២១. ការតែងតាំងអគ្គលេខាធិការ ម.ជ.ម. (២៩ វិច្ឆិកា ២០២២)

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានសម្រេចតែងតាំង កញ្ញា ម៉ាត់ ហ្វានីតា ដែលមានតំណែងជាអគ្គលេខាធិការស្តីទី ទៅជាអគ្គលេខាធិការ ដើម្បីបំពេញតួនាទី និងភារកិច្ចជាអគ្គលេខាធិការ របស់ ម.ជ.ម. ចាប់តាំងពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ តទៅ។

## ២២. វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់៥ & ៦ កម្រិតឧត្តម ២០២២ (១៥ ធ្នូ ២០២២)

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ម.ជ.ម. បានរៀបចំសវនាប្រតិដ្ឋផ្នែកពាណិជ្ជកម្ម ជូនដល់សិក្ខាកាមនៃវគ្គវណ្តុះបណ្តាលជំនាញមជ្ឈត្តការពាណិជ្ជកម្ម ជំនាន់ ៥ និង ៦ កម្រិតឧត្តម។





## ២៣. ពិធីប្រគល់វិញ្ញាបនបត្រ ជូនដល់បេក្ខជនដែលបានប្រឡងជាប់វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់ទី៥ និងជំនាន់ទី៦ (១៥ ធ្នូ ២០២២)

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំពិធីប្រគល់វិញ្ញាបនបត្រ ជូនដល់បេក្ខជនដែលបានប្រឡងជាប់វគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជំនាន់ទី៥ និងជំនាន់ទី៦ ព្រមជាមួយការចែកវិញ្ញាបនបត្រដល់បេក្ខជនដែលប្រឡងជាប់ក្នុងវគ្គបណ្តុះបណ្តាលស្តីពី "ការតាក់តែងមជ្ឈត្តវិនិច្ឆ័យ" ក្រោមអធិបតីភាពរបស់ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. ។ កម្មវិធីនេះត្រូវបានបញ្ចប់ដោយការពិសាអាហារពេលល្ងាចរួមគ្នា។





## ២៤. ការប្រកួតវគ្គចម្រុះ នៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិជ្ញផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២ ឆ្នាំ២០២២ (១២ ធ្នូ ២០២២)

នៅថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំការប្រកួតវគ្គចម្រុះ នៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិជ្ញផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២ ឆ្នាំ២០២២ ដោយមានអ្នកចុះឈ្មោះចូលរួមប្រកួតសរុបចំនួន ១២ ក្រុម។





## ២៥. ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រនៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិជ្ញផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២ ឆ្នាំ២០២២ (១៥ ធ្នូ ២០២២)

នៅព្រហស្បតិ៍ ៧រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ នៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិជ្ញផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២ ឆ្នាំ២០២២ ។





## ២៦. ការប្រកួតវគ្គផ្តាច់ព្រ័ត្រនៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិជ្ញផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២ ឆ្នាំ២០២២ (១៧ ធ្នូ ២០២២)

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំការប្រកួតវគ្គផ្តាច់ព្រ័ត្រ នៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិជ្ញផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២ ឆ្នាំ២០២២ នៅឯសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្រោមអធិបតីភាពរបស់ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. និង លោកបណ្ឌិត សេង ប៊ុនធឿន សាកលវិទ្យាធិការរង តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត ហោ ប៉េង សាកលវិទ្យាធិការ សាកលវិទ្យាល័យជាតិគ្រប់គ្រង។

ក្នុងការប្រកួតវគ្គផ្តាច់ព្រ័ត្រនេះផងដែរ ត្រូវបានផ្តល់កិត្តិយសចូលរួមជាគណៈកម្មការដាក់ពិន្ទុ (វេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករបីរូប) ដោយៈ

- លោកជំទាវ ខៀវ សុខា អនុប្រធានសាលាឧទ្ធរណ៍រាជធានីភ្នំពេញ
- លោកមជ្ឈត្តករ ប៊ុន យូឌី អតីតប្រធាន ម.ជ.ម. និង

- ឯកឧត្តមបណ្ឌិត គង់ ផល្លៈ រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងជាអាជ្ញាកណ្ដាលការងារ







## ២៧. ពិធីប្រគល់ពានរង្វាន់ជូនដល់ជ័យលាភី និងការជួបជុំពិសារអាហារពេលល្ងាច នៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២ ឆ្នាំ២០២២

(១៧ ធ្នូ ២០២២)

នៅល្ងាចថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានរៀបចំពិធីចែកវិញ្ញាបនបត្រ និងពិសាភោជនីយអាហារ ជាមួយស្ថាប័នចូលរួមឧបត្ថម្ភ ស្ថាប័នចូលរួមគាំទ្រ គ្រូដឹកនាំ គណៈកម្មការវាយតម្លៃ មជ្ឈត្តករស្ម័គ្រចិត្ត គណៈកម្មការកំណែស្ម័គ្រចិត្ត ក្រុមការងារទាំងអស់ និង ក្រុមប្រកួតនៃកម្មវិធីប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២ ឆ្នាំ២០២២ នៅឯសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ។

ក្នុងកម្មវិធីប្រកួតមជ្ឈត្តការប្រតិដ្ឋផ្នែកពាណិជ្ជកម្មប្រចាំឆ្នាំលើកទី២ ឆ្នាំ២០២២ នេះផងដែរបានបញ្ចប់ទៅដោយរលូនជាស្ថាពរ និងទទួលបានជោគជ័យ ដោយមានការចូលរួមឧបត្ថម្ភពីស្ថាប័នចំនួន ១២ រួមមាន៖

១. ការិយាល័យមេធាវី សិទ្ធិស័ក្តិ
២. ក្រុមមេធាវី ដឹហ្វេក
៣. ការិយាល័យមេធាវី ប៊ុន និងសហការី
៤. ក្រុមហ៊ុនមេធាវី ម៉ារ និងសហការី
៥. ក្រុមហ៊ុនមេធាវី អេច ប៊ី អេស
៦. ក្រុមហ៊ុនមេធាវី ដ័ន & ដ័ន ភ្នំពេញ
៧. ការិយាល័យមេធាវី អ អេន ធី សុខ អេន ហេង
៨. ការិយាល័យមេធាវី សុក ស៊ីផាន់ណា និងសហការី
៩. ការិយាល័យមេធាវី ហាស្គី អេន ផាតនើរ
១០. ក្រុមហ៊ុនផ្តល់សេវាកម្មច្បាប់ DFDL
១១. ក្រុមមេធាវី ស្តាយវន្ត
១២. សាកលវិទ្យាល័យ ជាតិគ្រប់គ្រង។

ជាមួយគ្នានេះដែរ ម.ជ.ម. ក៏បានទទួលនូវការចូលរួមគាំទ្រពីស្ថាប័នចំនួន ៧ រួមមាន៖

១. គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
២. មជ្ឈមណ្ឌលនៃមជ្ឈត្តការអន្តរជាតិសិង្ហបុរី
៣. មជ្ឈមណ្ឌលនៃមជ្ឈត្តការអន្តរជាតិហុងកុង
៤. សាកលវិទ្យាល័យ ជាតិគ្រប់គ្រង
៥. សមាគមសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា
៦. សមាគមកម្មសិទ្ធិបញ្ញាកម្ពុជា
៧. សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។








## ២៨. សិក្ខាសាលាស្តីពីមជ្ឈត្តករពាណិជ្ជកម្មនៅកម្ពុជា និងការយល់ដឹងអំពី ម.ជ.ម.

(១៩ មករា ២០២៣)

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ម.ជ.ម. បានសហការរៀបចំសិក្ខាសាលាស្តីពី "មជ្ឈត្តករពាណិជ្ជកម្មនៅកម្ពុជា និងការយល់ដឹងអំពី ម.ជ.ម." ជាមួយសភាពាណិជ្ជកម្មអ៊ឺរ៉ុបនៅកម្ពុជា ដោយមានការចូលរួមពីសំណាក់សហគមអ្នកជំនួញ។ នៅក្នុងសិក្ខាសាលានេះ មានវេទិកាពិភាក្សាចំនួនពីរដែលផ្តោតសំខាន់ទៅលើ៖

១. វិវាទលើវិស័យសំណង់ និងអចលនទ្រព្យ និង

២. វិវាទលើវិស័យពាណិជ្ជកម្ម និងសាជីវកម្ម។





## ២៩. ដំណើរទស្សនកិច្ចសិក្សាពីវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (០១ កុម្ភៈ ២០២៣)

នៅព្រឹកថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានទទួលស្វាគមន៍ដំណើរទស្សនកិច្ចសិក្សារបស់និស្សិតចំនួន ៣១ រូប ដែលដឹកនាំដោយលោកសាស្ត្រាចារ្យ ផន ឈៀងឡេង នៃកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រមកពី វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA) នៅទីស្នាក់ការមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ( ម.ជ.ម.)។ ការធ្វើទស្សនកិច្ចសិក្សានេះ គឺក្នុងគោលបំណងបង្កើននូវចំណេះដឹងផ្នែកមជ្ឈត្តការនៅកម្ពុជា។ កញ្ញាអគ្គលេខាធិការ ម៉ាត់ ហ្វានីតា បានធ្វើបទបង្ហាញអំពីវឌ្ឍនភាព និងតួនាទីរបស់ ម.ជ.ម. ក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា ព្រមទាំងធ្វើការចែករំលែកនូវបទពិសោធន៍ ក៏ដូចជាការឆ្លើយសំណួរ និងសំណេះសំណាលជាមួយនិស្សិតទាំងអស់ផងដែរ។





## ៣០. ការប្រឡងដើម្បីទទួលបានលក្ខណសម្បត្តិដូចមានចែងក្នុងមាត្រា ១២.១ (ឃ) (០៤ កុម្ភៈ ២០២៣)

នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ ម.ជ.ម. បានរៀបចំការប្រឡងដើម្បីទទួលបានលក្ខណសម្បត្តិដើម្បីចុះបញ្ជីជាមជ្ឈត្តករដូចមានចែងក្នុងប្រការ ១២.១ (ឃ) នៃបទបញ្ជាផ្ទៃក្នុងរបស់ ម.ជ.ម. ដែលមានបេក្ខជនចូលរួមប្រឡងចំនួន ៣០ (សាមសិប) រូប ហើយជាលទ្ធផលបេក្ខជន ចំនួន ២៤ (ម្ភៃបួន) រូប ទទួលបានជោគជ័យចំពោះការប្រឡងនេះ។

**៣១. វេទិកាពិភាក្សាជាសាធារណៈ លើវិធានស្តីពីសន្ធានកម្ម** (២២ កុម្ភៈ ២០២៣)

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានសហការរៀបចំសិក្ខាសាលាស្តីអំពី៖ "ការពិគ្រោះយោបល់ជាសាធារណៈទៅលើវិធានស្តីពីសន្ធានកម្ម និងក្រមសីលធម៌សម្រាប់សន្ធានការី" ជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដោយមានការគាំទ្រពី Swiss Cooperation Office and Consular Agency នៃព្រះរាជាណាចក្រកម្ពុជា (Swiss Confederation)។ ការពិគ្រោះយោបល់នេះផងដែរមានការអញ្ជើញចូលរួមពីសំណាក់អ្នកចូលរួមជាតិ និងអន្តរជាតិ សរុបចំនួន ១៥០ រូប ដែលបានផ្តល់ជាគុចូលមួយចំនួនទៅលើសេចក្តីព្រាងវិធានស្តីពីសន្ធានកម្ម និងក្រមសីលធម៌សម្រាប់សន្ធានការីរបស់ ម.ជ.ម. នៅសណ្ឋាគារ ហៃយ៉ាតរីជិនស៊ី ភ្នំពេញ។






**៣២. សិក្ខាសាលាអនឡាញស្តីអំពីតួនាទីរបស់អ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ**

(២៤ កុម្ភៈ ២០២៣)

នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ លោកមជ្ឈត្តករ សាន គីរី ប្រធាន ម.ជ.ម. និងលោកមជ្ឈត្តករ គឹម សាន អនុប្រធាន ម.ជ.ម. បានផ្តល់កិត្តិយសធ្វើជាវាគ្មិនក្នុងសិក្ខាសាលាអនឡាញស្តីអំពី "តួនាទីរបស់អ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ" ដែលមានអ្នកចូលរួមសរុបចំនួន ៩០ រូប។ សិក្ខាសាលានេះផងដែរមានគោលបំណងផ្សព្វផ្សាយដល់សាធារណជន ឱ្យយល់កាន់តែច្បាស់អំពី "វគ្គបណ្តុះបណ្តាលស្តីពីជំនាញអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការ ជំនាន់១" និងធ្វើការចុះឈ្មោះសិក្សា។

## ស្ថិតិសំណុំរឿង

របាយការណ៍ស្ថិតិនៃសំណុំរឿងមជ្ឈត្តកម្មនេះត្រូវបានធ្វើឡើងក្នុងគោលបំណងជម្រាបជូនសមាជិកនូវព័ត៌មាននៃការរីកឡើងនៃចំនួនសំណុំរឿងនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.)។ តួរលេខនៃការកើនឡើងនៃសំណុំរឿងជាកត្តាដែលសំខាន់ក្នុងការពង្រីកហេដ្ឋារចនាសម្ព័ន្ធនៃមជ្ឈមណ្ឌល ក៏ដូចជាការបង្កើន និងពង្រឹងធនធានមនុស្សនៃអគ្គលេខាធិការដ្ឋាន ម.ជ.ម. ផងដែរ។

បើទោះបីជាចំនួនសំណុំរឿងនៅមានចំនួនកំណត់ ក៏មានការបង្ហាញថាមានការដាក់បញ្ចូលនូវកិច្ចសន្យាមជ្ឈត្តកម្មទៅក្នុងកិច្ចសន្យាពាណិជ្ជកម្មពីមួយឆ្នាំទៅមួយឆ្នាំ ក៏ដូចជាការកើនឡើងនៃនិន្នាការនៃការប្រើប្រាស់មជ្ឈត្តកម្មជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

ទំហំវិវាទសរុប លក្ខណៈនៃវិវាទ ជាតិសាសន៍នៃគូភាគីនិងមជ្ឈត្តករ ព្រមទាំងភាសានៃមជ្ឈត្តកម្មបានឆ្លុះបញ្ចាំងអំពីសមត្ថភាពនៃ ម.ជ.ម. ក្នុងការគ្រប់គ្រងសំណុំរឿងដែលមានលក្ខណៈអន្តរជាតិ សំណុំរឿងដែលមានលក្ខណៈស្មុគស្មាញ ក៏ដូចជាការបង្ហាញអោយឃើញថាកម្ពុជាក៏ជាទីកន្លែងនៃមជ្ឈត្តកម្មអន្តរជាតិផងដែរ។

1. **ព័ត៌មានទូទៅ**

គិតចាប់ពីឆ្នាំ២០១៥ ដល់ធមាសទី១ នៃឆ្នាំ២០២៣ មានសំណុំរឿងមជ្ឈត្តកម្មចំនួន៣២ សំណុំរឿងត្រូវបានដាក់មក ម.ជ.ម. មានទំហំវិវាទសរុបប្រហែល ៩១ លានដុល្លារអាមេរិក។ ក្នុងសំណុំរឿងមជ្ឈត្តកម្មទាំង ៣២ សំណុំរឿង មាន ៦៨% ជាសំណុំរឿងដែលមានលក្ខណៈក្នុងស្រុក និង ៣២% សំណុំរឿងមានលក្ខណៈអន្តរជាតិ។ សំណុំរឿងក្នុងឆ្នាំ ២០១៨ និងឆ្នាំ២០២០ ជាឆ្នាំដែលមានសំណុំរឿងច្រើនជាងគេដែលមានអត្រា ២៥% និង ២៨% នៃសំណុំរឿងសរុប។ គិតចាប់ពីឆ្នាំ២០២២ រហូតដល់ធមាសទី១ នៃឆ្នាំ២០២៣ ម.ជ.ម. ទទួលការចុះបញ្ជីសំណុំរឿងចំនួន ០៤ សំណុំរឿង។ មិនមែនគ្រប់សំណុំរឿងសុទ្ធតែត្រូវបានទទួលមកគ្រប់គ្រងដោយ ម.ជ.ម. នោះទេ ដោយហេតុសំណុំរឿងមួយចំនួន ម.ជ.ម. មិនមានយុត្តាធិការ និង មួយចំនួនត្រូវបានសុំដកវិញដោយគូភាគីវិវាទ។ ៥៣% នៃសំណុំរឿងទាំង៣២ ត្រូវបានចេញមជ្ឈត្តវិនិច្ឆ័យ និង ១៨% ទៀតជាសំណុំរឿងដែលកំពុងដំណើរការ។



2. **ព័ត៌មាននៃសំណុំរឿង**

### ក. ទំហំវិវាទ

វិវាទនៃសំណុំរឿងនីមួយៗមានចាប់ពី ៦០០០ ដុល្លារអាមេរិក រហូតដល់ ២៩.០០០.០០០ ដុល្លារអាមេរិក។ ទំហំវិវាទនៃសំណុំរឿងមិនប៉ះពាល់លើដំណើរការ ឬសុពលភាពនៃសំណុំរឿងឡើយ នៅពេលដែល ម.ជ.ម. មានយុត្តាធិការលើសំណុំរឿង និងភាគីវិវាទគោរពតាមនីតិវិធីដែលបានកំណត់




### ខ. ស្ថានភាពនៃសំណុំរឿង




ក្នុងចំណោមសំណុំរឿងទាំង៣២ មាន៥៣% (១៧សំណុំរឿង) ត្រូវបានចេញនូវមេដ្ឋត្តវិនិច្ឆ័យដោយជោគជ័យ ដែលក្នុងនោះមានមេដ្ឋត្តវិនិច្ឆ័យមួយជាមេដ្ឋត្តវិនិច្ឆ័យដោយការព្រមព្រៀង។ វិធានស្តីពីមេដ្ឋត្តការ ឆ្នាំ២០២១ បានផ្តល់នូវនីតិវិធីមេដ្ឋត្តករបន្ទាន់ និងនីតិវិធីពន្លឿន ដែលមកដល់ឆមាសទី១នៃឆ្នាំ២០២៣ ម.ជ.ម. បានគ្រប់គ្រងសំណុំរឿង ០១ តាមនីតិវិធីពន្លឿន និង ០១ តាមយន្តការមេដ្ឋត្តករបន្ទាន់។

### គ. ភាគីវិវាទ

យោងតាមចំនួនសំណុំរឿងសរុបរបស់ ម.ជ.ម. មាន ៧១ភាគីមកពីយុត្តាធិការ ចំនួន៦ បានចូលរួមក្នុងដំណើរការមេដ្ឋត្តការ ដែលមានភាគីប្តឹងទាមទារ ចំនួន៣៣ (១៣ ភាគីជារូបវន្តបុគ្គល និង ២០ ភាគីជានីតិបុគ្គល) និងភាគីឆ្លើយតប ចំនួន៣៨ (២៣ ភាគីជារូបវន្តបុគ្គល និង ១៥ ភាគីជានីតិបុគ្គល)។ ក្នុងនោះផងដែរមាន សំណុំរឿងចំនួន ០១ ដែលមានភាគីប្តឹងទាមទារច្រើនជាងមួយភាគី និងសំណុំរឿងចំនួន ០៤ ដែលមានភាគីឆ្លើយតបច្រើនជាងមួយភាគី។ បើទោះបីជាភាគីនៃវិវាទមានសញ្ជាតិខ្មែរមានចំនួនច្រើនជាងសញ្ជាតិដទៃក៏ដោយ ចំនួននៃភាគីនៃវិវាទមានសញ្ជាតិបរទេសក៏មានការកើនឡើងដែល មានចំនួន ២៩% នៃចំនួនភាគីសរុប។ ម.ជ.ម សង្កេតឃើញថា ភាគីវិវាទសញ្ជាតិចិន មានចំនួនច្រើនជាងគេ ក្នុងចំណោមភាគីវិវាទដែលមានសញ្ជាតិបរទេសផ្សេងៗទៀត (១៣% នៃចំនួននៃគូភាគីវិវាទ)។







## គ. លក្ខណៈនៃវិវាទ




ម.ជ.ម. បានទទួលសំណុំរឿងវិវាទដែលទាក់ទងនឹងវិស័យពាណិជ្ជកម្មអន្តរជាតិ វិស័យសាងសង់ វិស័យធនាគារ និងហិរញ្ញវត្ថុ និងវិស័យអចលនទ្រព្យ ក៏ដូចជាវិស័យផ្សេងៗផងដែរ។ វិវាទលើអចលនទ្រព្យមានចំនួន ៤១% នៃចំនួនសំណុំរឿងសរុប ហើយវិវាទលើបញ្ហាហិរញ្ញវត្ថុមានចំនួន ១៩% នៃចំនួនសំណុំរឿងសរុប។

ក្នុងសំណុំរឿងមជ្ឈត្តកម្មរបស់ ម.ជ.ម. វិវាទដែលកើតចេញពីកិច្ចសន្យាកម្ចីសំណុំរឿងមានចំនួនច្រើនជាងគេ។បន្ទាប់ពីនេះវិវាទដែលកើតចេញពីកិច្ចសន្យាជួល និងកិច្ចសន្យាទិញ លក់ មានចំនួនស្មើគ្នា ដែលក្នុងនោះផងដែរ ក៏មានវិវាទដែលកើតចេញពីកិច្ចសន្យាបញ្ញើហិរញ្ញវត្ថុ ផងដែរ។



### ឃ. ដំណើរការមជ្ឈត្តការ




យើងសង្កេតឃើញថា បើទោះជាសំណុំរឿងគ្រប់គ្រងដោយ ម.ជ.ម. ភាគច្រើនមានលក្ខណៈក្នុងស្រុក ក៏ ៤៧%នៃសំណុំរឿងសរុបត្រូវបានធ្វើឡើងជាភាសាអង់គ្លេស និងនៅសល់៥៣% ត្រូវបានធ្វើឡើងជាភាសាខ្មែរ។ សំណុំរឿងដែលត្រូវធ្វើឡើងជាភាសាខ្មែរ ឬអង់គ្លេស ត្រូវបានគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងមានព្រះរាជាណាចក្រកម្ពុជា ជាទីកន្លែងនៃមជ្ឈត្តការ។

# រចនាសម្ព័ន្ធស្ថាប័ន

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) មានសមាជិករួមមាន៖ រូបវន្តបុគ្គលជាមជ្ឈត្តករ សមាគមអ្នកជំនួញ សមាគមវិជ្ជាជីវៈ (មហាសន្និបាត)។ មហាសន្និបាតធ្វើការបោះឆ្នោតជ្រើសតាំង ក្រុមប្រឹក្សាប្រតិបត្តិ រៀងរាល់បីឆ្នាំម្តង ដើម្បីគ្រប់គ្រងដំណើរការប្រព្រឹត្តិទៅប្រចាំថ្ងៃរបស់ ម.ជ.ម. ដោយមានជំនួយពីអគ្គលេខាធិការដ្ឋាន។ ក្រុមប្រឹក្សាប្រតិបត្តិអាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការសម្រាប់បំពេញកិច្ចការ ឬគម្រោងនានា។ តាមសំណូមពររបស់ក្រុមប្រឹក្សាប្រតិបត្តិ ក្រុមប្រឹក្សាពិគ្រោះយោបល់អាចផ្តល់យោបល់ជំនាញ និងជំនួយផ្នែកបច្ចេកទេសដល់ ម.ជ.ម. ទៅលើបញ្ហាពាក់ព័ន្ធនានា។



# ក្រុមប្រឹក្សាប្រតិបត្តិ
# អាណត្តិទី៤

ក្រុមប្រឹក្សាប្រតិបត្តិត្រួតពិនិត្យលើប្រតិបត្តិការប្រចាំថ្ងៃរបស់មជ្ឈមណ្ឌល។ ការកសាង និងអនុវត្តគោលនយោបាយរបស់ ម.ជ.ម. តាក់តែងវិធានថ្មី ឬវិសោធនកម្មលើវិធាន និងនីតិវិធីរបស់ ម.ជ.ម. តែងតាំងអគ្គលេខាធិការ និងមន្ត្រីអគ្គលេខាធិការដ្ឋាន។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតជ្រើសតាំងដោយមហាសន្និបាតសម្រាប់អាណត្តិបីឆ្នាំ។ ប្រសិនបើទទួលបានការបោះឆ្នោតជ្រើសតាំងនៅកិច្ចប្រជុំមហាសន្និបាត ក្រុមប្រឹក្សាប្រតិបត្តិអាចបំពេញតួនាទីច្រើនបំផុតត្រឹមពីរអាណត្តិជាប់គ្នា លើកលែងតែហេរញ្ញិក ។ មហាសន្និបាតប្រចាំឆ្នាំលើកទី៨ របស់ ម.ជ.ម. បានបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិអាណត្តិទី៤ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២។



មជ្ឈត្តករ សាន គីរី
ប្រធាន



មជ្ឈត្តករ គឹម សាន
អនុប្រធាន



មជ្ឈត្តករ លឹម វាសនា
ហេរញ្ញិក



មជ្ឈត្តករ ញាន សុមុន្និទ្ធ
សមាជិក



មជ្ឈត្តករ សូ មូស្សេន្នី
សមាជិក



មជ្ឈត្តករ តែ ពន្លឺ
សមាជិក



លោក វ៉ាន់ យុវទេព
សមាជិក
(តំណាងសភាពាណិជ្ជកម្មអឺរ៉ុប)

## គណៈកម្មាធិការតែងតាំង និងនីតិវិធី



មជ្ឈត្តករ សាន គីរី
ប្រធានគណៈកម្មាធិការ



មជ្ឈត្តករ ញាន សុមុន្និទ្ធ
សមាជិក



មជ្ឈត្តករ ឈឿន សុភាព
សមាជិក



មជ្ឈត្តករ លី សំបូរ
សមាជិក



មជ្ឈត្តករ ម៉ម រិទ្ធា
សមាជិក



មជ្ឈត្តករ សួស ស៊ីនួន
សមាជិក



មជ្ឈត្តករ សេង វុត្ថា
សមាជិក



មជ្ឈត្តករ អ៊ឹម សំអាន
សមាជិក



មជ្ឈត្តករ ខេត ឈិន
សមាជិក

## គណៈកម្មាធិការសមាជិកភាព



មជ្ឈត្តករ លឹម វាសនា
ប្រធានគណៈកម្មាធិការ



មជ្ឈត្តករ តែ ពន្លឺ
សមាជិក



មជ្ឈត្តករ ណុប សុខា
សមាជិក



មជ្ឈត្តករ ចាប កែវ
សមាជិក



មជ្ឈត្តករ ហ៊ឹង សៅលិញ
សមាជិក

## គណៈកម្មាធិការអប់រំ និងបណ្តុះបណ្តាល



មជ្ឈត្តករ គឹម សាន
ប្រធានគណៈកម្មាធិការ



លោក វ៉ាន់ យុវទេព
អនុប្រធាន



មជ្ឈត្តករ យស់ សូលី
សមាជិក



មជ្ឈត្តករ ឡុង ប៊ាង
សមាជិក



មជ្ឈត្តករ Jay Bryan COHEN
សមាជិក



មជ្ឈត្តករ Edmund Jerome KRONENBURG
សមាជិក



មជ្ឈត្តករ Djamel EL AKRA
សមាជិក



មជ្ឈត្តករ ផង ឈៀងឡេង
សមាជិក



មជ្ឈត្តករ យុន ចាន់នឿន
សមាជិក



មជ្ឈត្តករ អន ប៊ុនណារិទ្ធ
សមាជិក

## គណៈកម្មាធិការវិន័យ



មជ្ឈត្តករ សូ មូស្សេន្នី
ប្រធានគណៈកម្មាធិការ



មជ្ឈត្តករ កុយ នាម
សមាជិក



មជ្ឈត្តករ សារិន ដេណូរ៉ា
សមាជិក



មជ្ឈត្តករ គីរី សេរីរដ្ឋ
សមាជិក

# ក្រុមការងារអគ្គលេខាធិការដ្ឋាន

ចំណេះដឹងផ្នែកមជ្ឈត្តការត្រូវបានកំណត់ជាលក្ខណសម្បត្តិចាំបាច់ក្នុងការជ្រើសរើសក្រុមការងារ នៃអគ្គលេខាធិការដ្ឋាន។ ការដាក់បញ្ចូលនូវលក្ខណសម្បត្តិនេះ រួមចំណែកដល់ការលើកកម្ពស់សមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន ដើម្បីធានាឱ្យបាននូវឯករាជភាព និងសមត្ថភាពក្នុងការគ្រប់គ្រងសំណុំរឿងប្រកបដោយប្រសិទ្ធភាព។ ចាប់តាំងពីឆ្នាំ ២០២២ ក្រុមការងារថ្មីចំនួន ៣ រូប ត្រូវបានជ្រើសរើសឱ្យមកបំពេញការងារនៅអគ្គលេខាធិការដ្ឋាន ដែលពួកគេទាំងអស់មានចំណេះដឹងច្បាស់លាស់លើវិស័យមជ្ឈត្តការ។ ការជ្រើសរើសក្រុមការងារបន្ថែមនឹងមានជាបន្តបន្ទាប់នាពេលខាងមុខ។



កញ្ញា ម៉ាត់ ហ្វានីតា
អគ្គលេខាធិការ



កញ្ញា វ៉ាន់ មួយលាង
អ្នកគ្រប់គ្រងប្រតិបត្តិការ



លោក ឃុត ឧត្តម
អ្នកគ្រប់គ្រងសំណុំរឿង



លោក ស៊ូ រស្មី
ជំនួយការរដ្ឋបាល
និងហិរញ្ញវត្ថុ



កញ្ញា គី សុខលីម
ជំនួយការវគ្គបណ្តុះបណ្តាល



កញ្ញា សូ ឡៃនធីតា
ជំនួយការផ្នែកច្បាប់



លោក សុភាព ដារ៉ាវីន
ជំនួយការផ្នែកច្បាប់



លោក ចាន់ ដាវីត
ជំនួយការផ្នែកច្បាប់

# Activity Report 2022 and First Quarter 2023

## (April 2022 - February 2023)

**1. Election of President, Vice President, and Treasurer (30 March 2022)**

The Executive Board of the 4th mandate elected the President, Vice President and Treasurer organized by the Election Committee. The Executive Board of the 4th mandate has the following composition:

1. Arbitrator SAN Kiri, President of the Executive Board and NCAC
2. Arbitrator KIM San, Vice President of the Executive Board and NCAC
3. Arbitrator LIM Veasna, Treasurer of NCAC
4. Arbitrator NHEAN Somunin, Member of the Executive Board
5. Arbitrator SO Mosseny, Member of the Executive Board
6. Arbitrator TE Ponleou, Member of the Executive Board
7. Mr. VANN Yuvaktep, Representative of the European Chamber of Commerce in Cambodia and Member of the Executive Board.





**2. Virtual Webinar on "Arbitrator Profession in Cambodia" (21 April 2022)**

On 21 April 2022, NCAC organized a virtual workshop with the presence of Arbitrator SAN Kiri, President of the NCAC and Arbitrator KIM San, Vice-President of the NCAC as a speaker under the topic of: What is Arbitration? Who is the arbitrator? What power does the arbitrator have? How to become an arbitrator? What functions are arbitrator's incompatible with?
The virtual workshop went smoothly as the participants showed their interest in this profession.

**3. Mr. DIN Siden, Secretary General of NCAC, resigned from his position. (29 April 2022)**

Mr. Din Siden, Secretary General of the NCAC, resigned. On behalf of the NCAC, the Executive Board appreciated his hard work, contributions, and outstanding achievements over the past year for NCAC. Lastly, NCAC wishes him the best of luck and success in his future endeavors.





